fidh

CHRAC
CAMBODIAN HUMAN RIGHTS ACTION COMMITTEE

# សេចក្ដីថ្លែងការណ៍រួម

## វិធានផ្ទៃក្នុងវិសោធនកម្មថ្មី៖ ប្រសិទ្ធភាពនៃការចូលរួមរបស់ជនរងគ្រោះ និងការធ្វើឱ្យប្រសើរឡើងនូវសំណង ប៉ុន្តែមិនទាន់ធានាសំរាប់ការអនុវត្ត

**ប៉ារីស-ភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០:** កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ កន្លងទៅនេះ នៅឯកិច្ចប្រជុំពេញលើកទី៨ ចៅក្រម នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើការអនុម័តទៅលើវិសោធនកម្មវិធានផ្ទៃក្នុងរបស់ខ្លួន។ ស្របពេលដែលស្វាគមន៍ចំពោះវឌ្ឍនភាពនៃការទទួលស្គាល់នូវអាណត្តិក្នុងការផ្ដល់សំណងដល់ដើមបណ្ដឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដំណើរការពិគ្រោះយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិល គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា（CHRAC）និង សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស （FIDH） សំដែងនូវការព្រួយបារម្ភចំពោះចៅក្រមក្នុងការខកខានអនុម័តកិច្ចការពារសំខាន់ៗ ដើម្បីឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិក្នុងការទទួលបានសំណងរបស់ជនរងគ្រោះ នៅមុនពេលដំណើរការកាត់សេចក្ដីសំណុំរឿង ០០២។

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា（CHRAC）និង សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស （FIDH） ស្វាគមន៍ចំពោះការណែនាំឱ្យមាននូវមធ្យោបាយបន្ថែមមួយដែលសំខាន់សំរាប់ផ្ដល់សំណងសមូហភាព និងផ្លូវចិត្ត ទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ បន្ថែមលើការផ្ដល់សំណងដែលត្រូវចេញសោហ៊ុយផ្ទាល់ពីសំណាក់ពិរុទ្ធជន យន្តការថ្មីនេះ នឹងផ្ដល់លទ្ធភាពឱ្យមានទំរង់សំណងសមូហភាពជាគំរោងផ្សេងៗ ដែលទទួលស្គាល់ដោយអង្គជំនុំជម្រះ។ គំរោងបែបនេះនឹងត្រូវរៀបចំធ្វើឡើង និងអនុវត្តន៍តាមរយៈកិច្ចសំរបសំរួលរបស់អង្គភាពគាំពារជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយដោយសហការជាមួយនឹងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងតួអង្គក្រៅតុលាការផ្សេងៗទៀត។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ យើងក៏មានការសោកស្ដាយដោយសារថា អង្គជំនុំជម្រះវិសាមញ្ញមិនផ្ដល់នូវការធ្វើវិសោធនកម្មណាមួយដែលបញ្ជាក់ឱ្យបានច្បាស់លាស់អំពីថវិកាសំរាប់អនុវត្តសំណង ដែលត្រូវសំរេចដោយតុលាការនោះទេ ឧទាហរណ៍ ដូចជា ត្រូវបង្កើតឱ្យមានថវិកាជាក់លាក់មួយ ឬយន្តការសំរាប់គ្រប់គ្រងថវិការនេះ ដើម្បីយកទៅអនុវត្តន៍គំរោងជាសំណងទាំងនោះ។ ជាវិបាក គឺថា ប្រភពធនធានថវិកានេះ នៅតែស្ថិតក្នុងភាពមិនច្បាស់លាស់ ហើយត្រូវការឱ្យមានការកំណត់បញ្ជាក់ថែមនៅតំណាក់កាលបន្ទាប់ទៀត។

ក្រុមអង្គការសង្គមស៊ីវិល ស្វាគមន៍ចំពោះការធ្វើវិសោធនកម្ម ដែលកាន់តែពង្រឹងឡើងថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងអង្គភាពគាំពារជនរងគ្រោះ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង អង្គការមិនមែនរដ្ឋាភិបាលនានា ពាក់ព័ន្ធនឹងការអនុវត្តសំណងសមូហភាព និងផ្លូវចិត្ត ព្រមទាំងវិធានការនានាដែលមិនសំរេចដោយតុលាការ ដែលត្រូវបានអនុម័តទទួលយកជាទូទៅដោយកិច្ចប្រជុំពេញអង្គ។ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា និងសហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស អំពាវនាវឱ្យមានការអនុវត្តនូវបទប្បញ្ញត្តិ

ទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព នៅខណៈពេលដែលកំពុងបន្តត្រៀមរៀបចំដំណើរការកាត់សេចក្តីសំណុំរឿង ០០២។

ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា និង សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស សំដែងនូវការសោកស្តាយចំពោះកិច្ចប្រជុំពេញដែលមិនបានទទួលនូវអនុសាសន៍នានា ដែលជួយធានាថា សំណងសមូហភាពសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈយុត្តិធម៌ និងគ្រប់គ្រាន់ ព្រមទាំងតាក់តែង ឱ្យមានវិធានផ្ទៃក្នុងដែលនឹងអាចដោះស្រាយនូវបញ្ហាឧបសគ្គមួយចំនួនដែលកើតឡើងនៅពេលអនុវត្តជាក់ស្តែង។ នៅក្នុង ន័យនេះ យើងសោកស្តាយដោយហេតុថា សំណើសុំរបស់យើងដែលបានសុំឱ្យមានភាពបត់បែនជាងមុននៅក្នុងរៀបចំនូវ សេចក្តីសន្និដ្ឋានតែមួយ និងកិច្ចធានាមានការដាក់បញ្ចូលនូវសំលេងរបស់អ្នកភាគតិចនៅសេចក្តីសន្និដ្ឋាននោះ មិនត្រូវបាន គិតគូរពិចារណាដោយអង្គចៅក្រម។ លើសពីនេះទៀត និងដោយពិចារណាទៅលើវ័យចំណាស់របស់ជនជាប់ចោទទាំងអស់ វាកាន់តែសំខាន់ថែមទៀតក្នុងការខិតខំធ្វើឱ្យបាននូវទំរង់សំណងសមូហភាពដែលមិនចេញសោហ៊ុយដោយពិរុទ្ធជនអាចធ្វើ ទៅបាន នៅក្រោយពេលពិរុទ្ធជននោះ ទទួលមរណភាព។

ជារួម យើងកោតសរសើរចំពោះកិច្ចប្រជុំពេញអង្គដែលបានអនុម័តនូវវិសោធនកម្មវិធានផ្ទៃក្នុង ដែលជាលើក ដំបូងបានគិតគូរផ្តល់នូវជំរើសមួយដែលមានលក្ខណៈទន់ភ្លន់ ដើម្បីទទួលស្គាល់នូវអាណត្តិក្នុងការផ្តល់សំណងរបស់អង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ យើងក៏នៅតែសង្ឃឹមថា ចៅក្រមនឹងប្រើប្រាស់ កិច្ចប្រជុំពេញអង្គលើកក្រោយ នៅដើមឆ្នាំក្រោយ សំរាប់ដាក់បញ្ចូលនូវវិធានការនានាបន្ថែមទៀតទៅក្នុងវិធានផ្ទៃក្នុង ដើម្បីធានាឱ្យមានការអនុវត្តនូវបទប្បញ្ញត្តិទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព និងពេញលេញ។

***<u>សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:</u>***

| | ឈ្មោះ | តួនាទី/អង្គការ-សមាគម | លេខទូរស័ព្ទ |
|---|---|---|---|
| ១ | **លោក ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC) និងប្រធានសំរបសំរួលគណៈកម្មាធិការ ប្រព្រឹត្តិកម្ម (CHRAC)[1] | ០១៦ ៨៤០ ០៨៤ |
| ២ | **Karine APPY** | មន្ត្រី នៃ សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) | ⁺៣៣១ ៤៣៥៥១៤១២ |
| ៣ | **Fabien Maitre** | មន្ត្រី នៃ សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) | ⁺៣៣១ ៤៣៥៥៥០១៩ |
| ៤ | **លោក សុក សំអឿន** | នាយកប្រតិបត្តិអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) | ០១២ ៩០១ ១៩៩ |
| ៥ | **លោក ហង្ស ឆាយា** | នាយកប្រតិបត្តិវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID) | ០១២ ៨៦៥ ៩១០ |

[1] CHRAC គឺជាសម្ព័ន្ធសមាគម-អង្គការមិនមែនរដ្ឋាភិបាលដែលមានសមាជិកចំនួន ២៣ ធ្វើការនៅក្នុងប្រទេសកម្ពុជាលើ វិស័យសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងជំនួយផ្នែកច្បាប់។